## យើងនៅទីនេះដើម្បីជួយអ្នក ប្រសិនបើ អ្នកបានទទួលសេចក្តីជូនដំណឹងអំពីថ្លៃឈ្នួលយឺត

យើងយល់ថានេះគឺជាពេលវេលាដ៏តានតឹងសម្រាប់អ្នក និងគ្រួសារអ្នក
បុគ្គលិករបស់យើងនឹងព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីផ្ទេរសំណួររបស់អ្នកទៅកាន់មនុស្សសមស្របដើម្បីឆ្លើយតប ឬភ្ជាប់អ្នកទៅធនធានសហគមន៍ដែលអាចជួយអ្នកបាន។

## តើខ្ញុំទាក់ទងនរណានៅ Tacoma Housing Authority ប្រសិនបើខ្ញុំមានសំណួរ?

សំណួរអំពីកិច្ចសន្យាជួល ឬថ្លៃឈ្នួលដែលនៅជំពាក់

សូមទាក់ទង់ទៅអ្នកគ្រប់គ្រងអចលនទ្រព្យរបស់អ្នកដែលបានរាយក្នុងសេចក្តីជូនដំណឹងដែលអ្នកបានទទួល។

សំណួរអំពីធនធាន និងការគាំទ្រដល់សហគមន៍

សូមទាក់ទងទៅក្រុមគាំទ្រ និងសិទ្ធិអំណាចអតិថិជន (Client Support & Empowerment, **CSE)**
អ៊ីមែល៖ Contact-CSE@tacomahousing.org
ទូរសព្ទ៖ (253) 682-1224

## ចូរដឹងអំពីសិទ្ធិរបស់អ្នកក្នុងនាមជាអ្នកជួល!

*តើកិច្ចព្រមព្រៀងអំពីសំណងសម្រាប់ជំងឺកូវីដ (Covid Repayment Agreement, CRA) គឺជាអ្វី?*

- CRA គឺជាកិច្ចព្រមព្រៀងរវាងអ្នកជួល និង THA ពេលដែលអ្នកជួលចុះហត្ថលេខាលើកិច្ចសន្យាបង់ថ្លៃឈ្នួលដែលបានជំពាក់នៅចន្លោះខែវិច្ឆិកា ឆ្នាំ 2022 និងខែមេសា ឆ្នាំ 2023 ជាចំនួនបណ្តាក់តិចតួចតាមពេលវេលា។
- ការខកបង់ប្រាក់ CRA ត្រឹមតែ 1 ដងអាចនាំឱ្យមានកំហុសក្នុងកិច្ចសន្យាជួលរបស់អ្នក។

*តើខ្ញុំធ្វើដូចម្តេចប្រសិនខ្ញុំនឹងមានការយឺតយ៉ាវចំពោះការបង់ប្រាក់?*

- ប្រសិនអ្នកអាចធ្វើការបង់ប្រាក់ពេញលើថ្លៃឈ្នួលពេញដែលមិនទាន់បានបង់ ប៉ុន្តែនឹងមានការខកខានកាលកំណត់តាមសេចក្តីជូនដំណឹង ចូរទាក់ទងទៅអ្នកគ្រប់គ្រងអចលទ្រព្យរបស់អ្នក ឬ CSE ភ្លាមៗដើម្បីជូនដំណឹងពួកគេអំពីស្ថានភាពរបស់អ្នក។

*តើខ្ញុំស្នើសុំបណ្តឹងសាទុក្ខបានដែរឬទេ ប្រសិនបើខ្ញុំបានទទួលបទពិសោធន៍ភាពលំបាក ហើយមិនអាចបង់ថ្លៃឈ្នួល?*

- បាទ/ចាស! សូមស្នើសុំបណ្តឹងសាទុក្ខក្នុងរយៈពេល 10 ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹង។ ត្រូវការសំណើជាលាយលក្ខណ៍អក្សរ។ អ្នកអាចស្នើសុំសវនាការក្រៅផ្លូវការតាមអនឡាញដោយចូលទៅកាន់គេហទំព័ររបស់ Tacoma Housing Authority៖ www.tacomahousing.org/resources/informal-hearing ឬទាក់ទងអ្នកគ្រប់គ្រងអចលនទ្រព្យ ឬក៏ CSE របស់អ្នក ប្រសិនបើអ្នកត្រូវការជំនួយ។
- សំណើបណ្តឹងសាទុក្ខអាចរកបានចំពោះតែគ្រួសារ THA នៅលើកម្មវិធីលំនៅឋានសាធារណៈ ឬបណ្ណធានាទូទាត់ប្រាក់ប៉ុណ្ណោះ។

តើខ្ញុំនៅតែត្រូវដាក់ពាក្យប្រកាសការផ្លាស់ប្តូរកាលៈទេសៈដែរឬទេ ប្រសិនបើប្រាក់ចំណូលរបស់ខ្ញុំបានផ្លាស់ប្តូរ?

- បាទ/ចាស! ស្នើសុំពាក្យប្រកាសការផ្លាស់ប្តូរកាលៈទេសៈដោយចូលទៅកាន់គេហទំព័ររបស់ Tacoma Housing Authority នៅ៖ www.tacomahousing.org/current-clients/change-of-circumstances ឬទាក់ទងទៅអ្នកគ្រប់គ្រង់អចលនទ្រព្យ ឬ CSE របស់អ្នក។

តើមានពេលវេលាគ្រប់គ្រាន់ក្នុងការស្នើសុំការសម្របសម្រួលដែលសមហេតុផលដែរឬទេ?

- បាទ/ចាស! សូមបំពេញទម្រង់បែបបទដោយចូលទៅកាន់គេហទំព័ររបស់ Tacoma Housing Authority៖ www.tacomahousing.org/current-clients/know-your-rights/reasonable-accommodation-requests ឬទាក់ទងទៅអ្នកគ្រប់គ្រង់អចលនទ្រព្យ ឬ CSE របស់អ្នកសម្រាប់ជំនួយ។

ខ្ញុំបានជួបអំពើហិង្សាក្នុងគ្រួសារក្នុងអំឡុងពេលជាអ្នកជួលរបស់ THA របស់ខ្ញុំ តើខ្ញុំមានសិទ្ធិដែរឬទេ?

- ○ បាទ/ចាស! អ្នកមានសិទ្ធិក្រោមច្បាប់សហព័ន្ធដែលហៅថា ច្បាប់ប្រឆាំងនឹងអំពើហិង្សាស្ត្រី (Violence Against Women Act, VAWA)។ សូមទាក់ទងអ្នកគ្រប់គ្រងអចលនទ្រព្យ ឬ CSE របស់អ្នកសម្រាប់ព័ត៌មាន និងជំនួយបន្ថែម។

## មានជំនួយផ្នែកច្បាប់ និងការសម្របសម្រួលដោយឥតគិតថ្លៃ

សូមទូរសព្ទទៅលេខ 311 ចូលទៅកាន់គេហទំព័រ tacomaprobono.org ទូរសព្ទទៅលេខ៖ (253) 572-5134
ឬចូលទៅកាន់គេហទំព័រ NWJUSTICE.ORG/eviction-help ទូរសព្ទទៅលេខ៖ 1-855-657-8387 ឬក៏ចូលទៅកាន់គេហទំព័រ centerforresolution.org ទូរសព្ទទៅលេខ៖ (253) 572-3657

## ធនធានសហគមន៍

| ប្រភេទធនធាន | តើនរណាអាចប្រើប្រាស់ធនធាននេះ? | ទាក់ទង |
|---|---|---|
| • សម្ភារផ្គត់ផ្គង់សាលាយុវជន<br>• មធ្យោបាយធ្វើដំណើររបស់សាលា<br>• អាហារពេលព្រឹក និងអាហារថ្ងៃត្រង់របស់សាលា | គ្រួសារដែលមានកូនគ្រប់អាយុចូលរៀន | Michelle Birge<br>ដែលជាទីប្រឹក្សាផ្នែកច្បាប់ McKinney Vento<br>(253)571-1498<br>អ៊ីមែល៖ mbirge@tacoma.k12.wa.us |
| • ជំនួយសាច់ប្រាក់ក្នុងគ្រាអាសន្នដែលអាចត្រូវបានប្រើប្រាស់សម្រាប់ការបណ្តេញចេញ អាហារ ទឹកភ្លើង វេជ្ជសាស្ត្រ និងតម្រូវការផ្សេងទៀត។ ជាធម្មតាអាចដាក់ពាក្យសុំបានរហូតដល់ $1250 | គ្រួសារនឹងត្រូវទទួលអត្ថប្រយោជន៍ខ្លះៗពីក្រសួងសេវាសុខភាពនិងសង្គម (Department of Social and Health Services, DSHS) និង **មិនមែនពីជំនួយបណ្តោះអាសន្នសម្រាប់ គ្រួសារដែលជួបការលំបាក (Temporary Assistance for Needy Families, TANF)** ទេ | ជំនួយក្នុងគ្រាអាសន្នពី DSHS<br>សូមទូរសព្ទទៅការិយាល័យតាមតំបន់របស់អ្នក<br>ឬដាក់ពាក្យតាមអនឡាញនៅគេហទំព័រ www.washingtonconnection.org |
| • ជំនួយថ្លៃឈ្នួលក្នុងគ្រាអាសន្ន (ចាប់ផ្ដើមថ្ងៃទី 10/01/2023)<br>• ជំនួយថាមពល | ដល់គ្រួសារមានចំណូលទាប ហើយត្រូវតែផ្តល់ឯកសារ | Metropolitan Development Council (MDC)<br>ទូរសព្ទទៅលេខ៖ (253) 383-3921<br>គេហទំព័រ៖ mdc-hope.org |
| • ជំនួយថ្លៃឈ្នួលក្នុងគ្រាអាសន្ន<br>• មណ្ឌលជំនួយសម្លៀកបំពាក់<br>• អាហារ<br>• កាតហ្គាស | ត្រូវតែជាអ្នកចូលរួមនៅក្នុងមណ្ឌលជំនួយសម្លៀកបំពាក់នៅ St. Francis<br><br>ត្រូវស្ថិតនៅក្នុងលេខកូដតំបន់ជាក់លាក់ | St. Francis<br>253-770-6991<br>322 7th Street SE Puyallup, WA 98372 |
| • អាចដេកមួយយប់នៅក្នុងឡានរបស់អ្នក<br>• ជាធម្មតាមានសុវត្ថិភាព<br>• ស្ថានីយសម្អាតខ្លួន និង បន្ទប់ទឹក<br>• ការសម្របសម្រួលសេវាកម្មនៅនឹងកន្លែង | សម្រាប់អ្នកគ្រប់គ្នា | កន្លែងចតរថយន្តប្រកបដោយសុវត្ថិភាព<br>pchomeless.org/Home/SafeParking3<br><br>ទំព័រនេះនឹងមានព័ត៌មានថ្មីបំផុតសម្រាប់ទំនាក់ទំនង/ទីតាំង |
| • ទីជម្រកគ្រាអាសន្ន<br>• លំនៅឋានរួម<br>• ជំនួយដល់ថ្លៃឈ្នួលផ្ទះ<br>• មធ្យោបាយធ្វើដំណើរ | ត្រូវតែកំពុងជួបប្រទះនឹងភាពគ្មានផ្ទះសម្បែង | ទូរសព្ទទៅលេខ៖ 211 |
| • ទឹកផ្កាឈូក<br>• កន្លែងបោកគក់<br>• អាគារផ្ទះបាយ<br>• កុំព្យូទ័រ<br>• បុគ្គលិកករណីនៅនឹងកន្លែង<br>• អ្នកជំនាញខាងទទួលយកអ្នកចូលស្នាក់ដោយមានការសម្របសម្រួល | ក្នុងមួយកន្លែងៗ៖ "គ្រួសារ" ត្រូវបានកំណត់និយមន័យថាជាឪពុកឬម្តាយ ឬទាំងពីរ ដែលមានកូនតូចក្នុងការថែទាំរបស់ខ្លួន ឬជាបុគ្គល "ដែលពពោះ"។ | Family Day Center<br>5050 S Tacoma Way<br>ទូរសព្ទទៅលេខ៖ 253-471-5340 |

## ពិព័រណ៍ធនធានឥតគិតថ្លៃសម្រាប់ការដាក់ពាក្យសុំជំនួយថ្លៃជួលនិងជំនួយផ្លូវច្បាប់

Tacoma Housing Authority នឹងរៀបចំពិព័រណ៍ធនធានឥតគិតថ្លៃ ដែលនឹងផ្តល់ជូនធនធាន និងជំនួយ ដល់អ្នកដើម្បីស្វែងយល់អំពីធនធានជំនួយថ្លៃឈ្នួល ជំនួយផ្លូវច្បាប់ ជំនួយដល់អ្នកមិនមានការងារធ្វើ និង ច្រើនទៀត។

| ថ្ងៃទី 4 ខែតុលា | ថ្ងៃទី 2 និងទី 5 ខែតុលា | ថ្ងៃទី 3 ខែតុលា |
|---|---|---|
| 2 រសៀល - 5 ល្ងាច<br>The Rise on 19th<br>1815 S. G Street | ថ្ងៃទី 2 ខែតុលា ម៉ោង 4 ល្ងាច - 7 យប់<br>(Tacoma Pro Bono Legal ប៉ុណ្ណោះ)<br>ថ្ងៃទី 5 ខែតុលា ម៉ោង 4 ល្ងាច - 7 យប់<br>Salishan Family Investment Center<br>1724 E 44th St. | 1 រសៀល – 4:30 ល្ងាច<br>Bay Terrace<br>2550 S G St |